# សុន្ទរកថារបស់លោក យូណាមីណេ ម៉ូរីយ៉ាស៊ូ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធអគារវេជ្ជសាស្ត្រ និងព្យាបាលជម្ងឺកុមារ ក្នុង
# មន្ទីរពេទ្យបង្អែកព្រៃកបាស ខេត្តតាកែវ
# ថ្ងៃទី០៩ ខែ មករា ឆ្នាំ ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!
- សូមគោរព ឯកឧត្តមវេជ្ជបណ្ឌិត សុខ ផេង រដ្ឋលេខាធិការក្រសួងសុខាភិបាល
- សូមគោរព ឯកឧត្តម គាវ សុវណ្ណធី អភិបាលរងខេត្តតាកែវ
- សូមគោរព លោកវេជ្ជបណ្ឌិត ហែម សារ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ
- សូមគោរព លោកវេជ្ជបណ្ឌិត ណាកាដា អ៊ីហ្សូ តំណាងអោយអង្គការតាកាហាស៊ីរ៉ូតារីក្លឹប
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីសម្ពោធអគារវេជ្ជសាស្ត្រ នៅមន្ទីរពេទ្យបង្អែកព្រៃកបាសនេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមវេជ្ជបណ្ឌិត សុខ ផេង។ ជាបឋមខ្ញុំ សូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមរដ្ឋលេខាធិការ ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការកសាងឡើងវិញ និងការអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏បានធ្វើអោយសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតរបស់ខ្លួន ស្មើនឹងបណ្ដាប្រទេសកំពុងរីកចំរើនក្នុងតំបន់អាស៊ាន។ នៅក្នុងវិស័យសុខាភិបាល ទាំងបរិមាណនិងគុណភាពមានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

រដ្ឋាភិបាលជប៉ុនបាននឹងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីធ្វើអោយប្រសើរឡើងនូវការថែទាំសុខភាព តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្ស និងការកែលម្អអគារថែទាំវេជ្ជសាស្ត្រ។

គម្រោងនេះ គឺដើម្បីសាងសង់អគារវេជ្ជសាស្ត្រ និងព្យាបាលជម្ងឺកុមារ និងបំពាក់ទៅដោយគ្រែអ្នកជម្ងឺនៅក្នុងមន្ទីរពេទ្យបង្អែកព្រៃកបាស។ ដោយសារតែចំនួនអ្នកជម្ងឺ នៅក្នុងមន្ទីរបង្អែកព្រៃកបាស មានការកើនឡើងយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំថ្មីៗនេះ ដែលធ្វើអោយអគារអ្នកជម្ងឺរបស់ខ្លួន មិនអាចទ្រទ្រង់បាននូវតម្រូវការកើនឡើងនៃចំនួនអ្នកជម្ងឺនៅមូលដ្ឋានបានឡើយ។ អគារវេជ្ជសាស្ត្រថ្មីនេះ ត្រូវបានគាំទ្រដោយជំនួយឥតសំណងទ្រង់ទ្រាយតូចរបស់ជប៉ុន នឹងអនុញ្ញាតអោយអ្នកជម្ងឺកាន់តែច្រើនឡើងទទួលបានការព្យាបាលប្រកបដោយសុវត្ថិភាព និងក្នុងបរិស្ថានប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដោយហេតុនេះយើងសង្ឃឹមថាគម្រោងនេះ នឹងរួមចំណែកជួយកែលម្អធ្វើអោយប្រសើរឡើងស្ថានភាពសុខភាពនៅក្នុងតំបន់។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារវេជ្ជសាស្ត្រ និងព្យាបាលជម្ងឺកុមារថ្មីនេះ នឹងពង្រីកការផ្ដល់សេវាសុខភាពបន្ថែមទៀតក្នុងខេត្តតាកែវ ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើន នឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខភាពដែលផ្ដល់ដោយមន្ទីរពេទ្យល្អប្រសើរជាងមុន ។ ខ្ញុំសង្ឃឹមថា មណ្ឌលសុខភាពនេះ នឹងត្រូវបានថែទាំ

យ៉ាងត្រឹមត្រូវ និងប្រើប្រាស់បានយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!